ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៨៩
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨
សាលដីកា
លេខ ៨៣ "II"
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

# សាលដីកា
## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ (កែប្រែមកជា ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨) របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្បន្ននៅផ្ទះ [redacted] រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៣ នាក់។ ទោសពីមុនគ្មាន។

Scanned with CamScanner

-ជាប់ចោទពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ភេទស្រី អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរ "ប្រធានការិយាល័យរដ្ឋបាលទូទៅ នៃនាយកដ្ឋានផែនការស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម" មានទីលំនៅបច្ចុប្បន្ននៅផ្ទះ [redacted] រាជធានីភ្នំពេញ។ (អ្នកប្តឹងសាទុក្ខ)

**អំពីអង្គហេតុ**

កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៥ ឈ្មោះ [redacted] វុត្ថា បានបញ្ចុះបញ្ចូលឱ្យឈ្មោះ [redacted] សុខា ភេទស្រី បម្រើការនៅនាយកដ្ឋានគណនេយ្យ នៃក្រសួងពាណិជ្ជកម្ម ឱ្យទូរស័ព្ទប្រាប់ទៅឈ្មោះ [redacted] សុជាតិ ជាប្តីរបស់ឈ្មោះ [redacted] សម្ផស្ស ថាឈ្មោះ [redacted] សម្ផស្ស មានទំនាក់ទំនងផ្នែកមនោសញ្ចេតនាលួចលាក់ជាមួយឈ្មោះ [redacted] រតនៈ ដែលបម្រើការនៅក្រសួងពាណិជ្ជកម្មជាមួយគ្នា ថែមទាំងសាកសួរពីស្ថានភាពគ្រួសារ និងអាកប្បកិរិយា របស់ឈ្មោះ [redacted] សម្ផស្ស ទៀតផង ក្នុងគោលបំណងឱ្យស្វាមី មិនទុកចិត្តភរិយា និងតាមដានរាល់សកម្មភាពរបស់ឈ្មោះ [redacted] សម្ផស្ស ទៀតផង។ ឈ្មោះ [redacted] សុខា បានប្រាប់ថាឈ្មោះ [redacted] សុជាតិ បន្ថែមទៀតថា បើចង់ដឹងរឿងច្បាស់ឱ្យទូរស័ព្ទទៅសួរឈ្មោះ [redacted] វុត្ថា ព្រោះឈ្មោះ [redacted] វុត្ថា ដឹងរឿងច្បាស់ ហើយខ្លួនទូរស័ព្ទមកប្រាប់នេះបញ្ហារបស់ឈ្មោះ [redacted] វុត្ថា ដែរ។ មិនតែប៉ុណ្ណោះឈ្មោះ [redacted] វុត្ថា បានដើរបរិហារកេរ្តិ៍អំពីទំនាក់ទំនងរវាងឈ្មោះ [redacted] សម្ផស្ស និងឈ្មោះ [redacted] រតនៈ នៅកន្លែងធ្វើការទៀតផង។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៥០៥ "ក" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១.ផ្តន្ទាទោសឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ ៤៣ឆ្នាំ សញ្ជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១០០.០០០ (មួយសែន) រៀល។

ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យឈ្មោះ [redacted] វុត្ថា សងសំណងជម្ងឺចិត្តចំនួន ១.០០០.០០០(មួយលាន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ និងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៦៦៩ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] វុត្ថា ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥០៥ "វ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចនៃសាលក្រមព្រហ្មទណ្ឌទាំងមូល។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៧១៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់លោកស្រី [redacted] សម្ផស្ស ជាមេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥០៥ "វ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចពិន័យជាប្រាក់ និងសំណងជម្ងឺចិត្ត។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ (កែប្រែមកជាថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨) របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១. ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៦៦៩ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] វុត្ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២. ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៧១៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់មេធាវីទទួលសិទ្ធិពីឈ្មោះ [redacted] សម្ផស្ស ទទួលសិទ្ធិពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់។

៣. បដិសេធចោលសាលក្រមព្រហ្មទណ្ឌលេខ ២៥០៥ "វ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

៤. សម្រេចឱ្យឈ្មោះ [redacted] វុត្ថា រួចខ្លួនពីបទចោទប្រកាន់ពីបទ៖ បរិហារកេរ្ដិ៍ជាសាធារណៈ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៤០៥ នៃក្រមព្រហ្មទណ្ឌ។

៥. សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] សម្ផស្ស ប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ។

បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ ដីកាសម្រេចកែតម្រូវលេខ ៣៥ ដ.ក.ឧ/១៨ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖

១-កែតម្រូវនៅលើទំព័រទី ១ ត្រង់ចំណុចសាលដីកាលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ មកជា ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ និងទំព័រទី ៦ បន្ទាត់ទី ១១ នៃសេចក្ដីសម្រេច ត្រង់ចំណុចកាលបរិច្ឆេទ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ មកជា ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ វិញ។

-ចំណុចផ្សេងពីនេះរក្សាទុកដដែល។



Scanned with CamScanner

២-បង្គាប់ឱ្យភ្ជាប់ដីកាសម្រេចនេះជាមួយសាលាដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សម្ផស្ស ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ (កែប្រែមកជាថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨) របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សារណាការពារ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] សម្ផស្ស។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា សាលាឧទ្ធរណ៍ បានសម្រេចឱ្យរួចផុតពីបទចោទ គឺមានលក្ខណៈត្រឹមត្រូវហើយ។ តំណាងមហាអយ្យការ សុំតម្កល់សាលដីកា សាលាឧទ្ធរណ៍ ទុកជាបានការដដែល ដោយឡែកដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងសាទុក្ខដោយផ្អែកនឹង បញ្ញត្តិមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានអនុភាពតែលើសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះហេតុដូច្នេះ សូមឯកឧត្តម ប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តា ពិចារណាតាមច្បាប់។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សោម សម្ផស្ស បានឆ្លើយថា៖ ខ្លួនបម្រើការងារនៅក្រសួងពាណិជ្ជកម្ម គឺខ្លួនបានគោរពម៉ោងពេលការងារជាមន្ត្រីរាជការណាស់ ប៉ុន្តែខ្លួនមានការងារមួយចំនួនផ្សេងទៀត ដែល ត្រូវធ្វើក្រៅម៉ោងការងារ ជាមួយលោក [redacted] រតនៈ ដែលជាម៉ោងទំនេររបស់ខ្លួន ដោយខ្លួនមិនបានរាយ ការណ៍ទៅថ្នាក់ដឹកនាំទេ ព្រោះគិតថាជាសិទ្ធិរបស់ខ្លួន ប៉ុន្តែឈ្មោះ [redacted] វុត្ថា បានចោទប្រកាន់រូបខ្លួនហើយ បានពឹងគេឱ្យទូរស័ព្ទទាក់ទងទៅគ្រួសាររបស់ខ្លួន(ប្តី) ថាខ្លួនដើរតែពីនាក់ [redacted] រតនៈ រហូតដល់ថ្នាក់ជួល គេឱ្យតាមដានពួកខ្លួន ទៅណាមកណាថ្ងៃសៅរ៍ ថ្ងៃអាទិត្យទៀត។ មិនត្រឹមតែប៉ុណ្ណោះទេ រាល់ថ្ងៃឈ្មោះ [redacted] វុត្ថា បានញុះញង់អ្នកនៅកន្លែងការងារឱ្យស្អប់ខ្ពើម និងមើលមកខ្លួនដូចសត្វចម្លែកអ៊ីចឹង។ លើសពី នេះទៅទៀត ឈ្មោះ [redacted] វុត្ថា បាននិយាយបរិហារកេរ្តិ៍ខ្លួនដល់គ្រួសាររបស់ឈ្មោះ [redacted] រតនៈ និងធ្វើឱ្យ ក្រុមគ្រួសារឈ្មោះ [redacted] រតនៈ មើលងាយ និងស្អប់ខ្ពើមមកលើរូបខ្លួន។ ហេតុដូច្នេះខ្លួនស្នើសុំតុលាការកំពូល ដែលជាស្ថាប័នចុងក្រោយ មេត្តារកយុត្តិធម៌ឱ្យខ្លួន និងដាក់ទោសចំពោះជនដែលធ្វើខុសផង។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] សម្ផស្ស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នាពេលសវនាការនៅតុលាការកំពូល និងសារណាការពារ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់អ្នកប្ដឹងសាទុក្ខឈ្មោះ [redacted] សម្ផស្ស បានបញ្ជាក់ថា នៅអំឡុងខែកក្កដា ឆ្នាំ២០១៥ ឈ្មោះ [redacted] វុត្ថា បានបញ្ចុះបញ្ចូលឱ្យឈ្មោះ [redacted] សុខា ភេទស្រី បម្រើការងារនៅក្រសួងពាណិជ្ជកម្មឱ្យទូរស័ព្ទទៅឈ្មោះ [redacted] សុជាតិ ត្រូវជាប្ដីរបស់ខ្លួនថា ខ្លួនមានទំនាក់ទំនងផ្លូវមនោសញ្ចេតនាលួចលាក់ជាមួយឈ្មោះ [redacted] រតនៈ ដែលបម្រើការងារនៅក្រសួងពាណិជ្ជកម្មជាមួយគ្នា ថែមទាំងឱ្យសាកសួរពីស្ថានភាពគ្រួសារ និងអាកប្បកិរិយារបស់ខ្លួន ក្នុងគោលបំណងធ្វើឱ្យស្វាមីខ្លួនមិនទុកចិត្តភរិយា និងតាមដានសម្មភាពរបស់ខ្លួនទៀតផង។ មិនតែប៉ុណ្ណោះ ឈ្មោះ [redacted] វុត្ថា បានដើរបរិហារកេរ្តិ៍ជាសាធារណៈ មកលើខ្លួនថាជាអ្នកផិតក្បត់ និងមានកាយវិការមាក់ងាយមកលើខ្លួន លើសពីនេះទៅទៀត ឈ្មោះ [redacted] វុត្ថា បាននិយាយបរិហារកេរ្តិ៍ខ្លួនដល់ក្រុមគ្រួសាររបស់ឈ្មោះ [redacted] រតនៈ និងធ្វើឱ្យក្រុមគ្រួសារឈ្មោះ [redacted] រតនៈ មើលងាយ និងស្អប់ខ្ពើមមកលើរូបខ្លួន។

ចំពោះការលើកឡើងរបស់អ្នកប្ដឹងសាទុក្ខខាងលើ គឺជាការលើកឡើងអំពីអង្គហេតុ ដែលត្រូវបានសាលាឧទ្ធរណ៍រកឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ច្បាស់ថា ឈ្មោះ [redacted] វុត្ថា ដើរបរិហារកេរ្តិ៍ ឈ្មោះរបស់ [redacted] សម្ផស្ស ដោយមានការដឹងឮជាសាធារណៈនោះឡើយ។ ម្យ៉ាងវិញទៀតជាការត្រឹមត្រូវហើយ ដែលសាលាឧទ្ធរណ៍យល់ឃើញថា ការដែលឈ្មោះ [redacted] សុខា ជាអ្នកទូរសព្ទ័ប្រាប់ប្ដីដើមបណ្ដឹងថា ឈ្មោះ [redacted] វុត្ថា ជាអ្នកផ្ដាំឱ្យឈ្មោះ [redacted] សុជាតិ តាមដានប្រពន្ធរបស់ខ្លួនថាមានអ្វីប្លែកអត់ ហើយបើចង់ដឹងច្បាស់ឱ្យទូរស័ព្ទសួរឈ្មោះ [redacted] វុត្ថា គឺពុំមែនមានន័យថាឈ្មោះ [redacted] វុត្ថា បានបរិហារកេរ្តិ៍ឈ្មោះ [redacted] សម្ផស្ស ឡើយ។

៣-យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ឈ្មោះ [redacted] សម្ផស្ស ពុំមានមូលហេតុនៃបណ្ដឹងសាទុក្ខតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្ដឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] សម្ផស្ស។



Scanned with CamScanner

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៤ ក្រVI "ប.ស" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍។

*សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។*

Scanned with CamScanner